សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# *សារលិខិត*

*របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*

*នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា*

*ក្នុងឱកាសទិវាសន្តិភាពអន្តរជាតិលើកទី ១៣*

*ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ២០១៥*

~~~~~

*- សូមថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*

*- ជនរួមជាតិជាទីស្នេហា!*

*ថ្ងៃនេះប្រជាជនកម្ពុជាទូទាំងប្រទេសមានសេចក្តីសោមនស្សរីករាយ ជាមួយប្រជាជនលើសកលលោក ប្រារព្ធ«ទិវាសន្តិភាពអន្តរជាតិ» ជារៀងរាល់ឆ្នាំ នៅថ្ងៃទី ២១ ខែ កញ្ញា ស្របតាមសេចក្តីសំរេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិលើកទី៥៥ នៅឆ្នាំ២០០១ ក្នុងគោលបំណងអប់រំ និងលើកកំពស់ការយល់ដឹងជាសាធារណៈឱ្យបានទូលំទូលាយអំពីអត្ថន័យ និងតំលៃនៃសន្តិភាព និងភាពចាំបាច់ក្នុងការរួមចំណែកដល់កិច្ចប្រឹងប្រែងជាអន្តរជាតិ សំដៅទប់ស្កាត់ កាត់បន្ថយ និងបញ្ឈប់រាល់ជំលោះដោយអាវុធ និងសង្គ្រាមនៅគ្រប់ទីកន្លែងទូទាំងសកលលោក។*

*«សន្តិភាព» ជាបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាជនទាំងអស់នៅក្នុងសកលលោក ជាពិសេសប្រជាជនកម្ពុជា ដែលបានឆ្លងកាត់សង្គ្រាមអស់ជិតពាទសវត្សរ៍ និងបណ្តាលឲ្យប្រជាជនយើងរាប់លាននាក់ បាត់បង់ជីវិតយ៉ាងខ្លោចផ្សារ ព្រាត់ប្រាស់គ្រួសារ និងរងទុក្ខវេទនាឥតឧបមា ក្នុងរបបប្រល័យពូជសាសន៍ប៉ុលពត។ ការឈឺចាប់ ការរងទុក្ខវេទនា និងភាពខ្លោចផ្សារទាំងនេះ នៅតែដិតជាប់ក្នុងអារម្មណ៍របស់ពលរដ្ឋកម្ពុជាគ្រប់រូប ដែលនាំឲ្យយល់ច្បាស់ណាស់ពីតម្លៃនៃ«សន្តិភាព»។*

*ការចូលរួមប្រារព្ធ «ទិវាសន្តិភាពអន្តរជាតិ» របស់យើងនៅពេលនេះ មិនត្រឹមតែបានឆ្លុះបញ្ចាំងពីឆន្ទៈមោះមុតរបស់ប្រជាជនកម្ពុជាក្នុងការការពារសន្តិភាពប៉ុណ្ណោះទេ តែជាឱកាសក្រើនរំលឹកពីភាពចាំបាច់ខានពុំបាននៃការពង្រឹងផែនសាមគ្គី ឯកភាពជាតិ ពួតដៃគ្នាជាធ្លុងមួយ រួមជាមួយប្រជាជនក្នុងសកលលោក ដើម្បីថែរក្សា ឱ្យបានគង់វង្សនូវសន្តិភាព ដែលជាគន្លឹះមិនអាចខ្វះបាននៃការអភិវឌ្ឍន៍ និងភាពរីកចម្រើននៃប្រទេសជាតិយើង។*
~~~~~

*ជនរួមជាតិជាទីស្នេហា!*

*នៅឆ្នាំ១៩៩៨ តាមរយៈនយោបាយ **ឈ្នះ-ឈ្នះ** អង្គការចាត់តាំងនយោបាយនិងយោធានៃរបបប្រល័យពូជសាសន៍ប៉ុលពតត្រូវបានផ្តួលរំលំ និងសង្គ្រាមដ៏រ៉ាំរ៉ៃជិតបីទសវត្សរ៍នៅលើទឹកដីមាតុភូមិកម្ពុជារបស់យើងត្រូវបានបញ្ចប់ទាំងស្រុង ហើយបាននាំមកវិញនូវសន្តិភាព និងការឯកភាពជាតិលើទឹកដីកម្ពុជាយ៉ាងពេញលេញ។ ប្រជាជនកម្ពុជាទាំងមូលមានមោទនភាពចំពោះសមិទ្ធិផលជាតិដ៏ឧត្តុងឧត្តមនេះ និងប្តេជ្ញារួមសាមគ្គីការពារសមិទ្ធផលនេះឱ្យបានគង់វង្ស និងទប់ស្កាត់រាល់ឧបាយកល និងការប៉ុនប៉ងតាមគ្រប់រូបភាពសំដៅធ្វើឱ្យប្រទេសជាតិធ្លាក់ចូលក្នុងភាពវឹកវរ អស្ថិរភាពសង្គម និងបាត់បង់សន្តិភាព។*

*ក្រោយពីទទួលបានសន្តិភាពពេញលេញ កម្ពុជាបានខិតខំអភិវឌ្ឍន៍ប្រទេសជាតិលើគ្រប់វិស័យ ព្រមទាំងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ស្របតាម**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១, ទី២ និងទី៣** សព្វថ្ងៃនេះរបស់រាជរដ្ឋាភិបាល។ ប្រជាជនកម្ពុជាទាំងមូលមានសេចក្តីសប្បាយរីករាយក្នុងការទទួលផលពីសុខសន្តិភាព ស្ថេរភាពនយោបាយ សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ព្រមទាំងការអភិវឌ្ឍសេដ្ឋកិច្ច និងមានជីវភាពកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ ជាក់ស្តែងជាងពីទសវត្សរ៍ចុងក្រោយ កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចជាមធ្យមប្រចាំឆ្នាំ (GDP) **៧.៧%** ក្នុងមួយឆ្នាំ ហើយនៅឆ្នាំ ២០១៤ កំណើនសេដ្ឋកិច្ចកម្ពុជាសម្រេចបាន **៧,២%** និងរំពឹងថា មិនទាបជាង **៧%** នៅឆ្នាំ២០១៥នេះ។ ដោយឡែកផលិតផលក្នុងស្រុកសរុប សំរាប់មនុស្សម្នាក់ៗកើនពីចំនួន **៧៦០** ដុល្លាអាមេរិក ក្នុងឆ្នាំ ២០០៨ មក ១.០៤៣ ដុល្លាអាមេរិកនៅ ក្នុងឆ្នាំ ២០១៣ និងបានកើនឡើងដល់ ១,១៣០ ដុល្លាអាមេរិក ក្នុងឆ្នាំ ២០១៤ ហើយនៅឆ្នាំ២០១៥ អាចកើនដល់ **១,២២៥** ដុល្លាអាមេរិក ដែលធ្វើឲ្យកម្ពុជាឈានដល់ដំណាក់កាលថ្មីមួយទៀតគឺកំពុងក្លាយជាប្រទេសមានចំណូលមធ្យម (កម្រិតទាប)។*

*ទន្ទឹមនឹងការរីកចម្រើនក្នុងវិស័យសេដ្ឋកិច្ចនិងសង្គម ការលើកស្ទួយនីតិរដ្ឋ ការអនុវត្តលទ្ធិប្រជាធិបតេយ្យ និងការការពារសិទ្ធិមនុស្សក៏កំពុងមានដំណើរការល្អនៅក្នុងក្របខណ្ឌរដ្ឋធម្មនុញ្ញ ច្បាប់ប្រទេសជាតិ និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធមនុស្ស ដើម្បីធានាឲ្យបានជូនប្រជាពលរដ្ឋគ្រប់រូបនូវសិទ្ធិសេរីភាពជាមូលដ្ឋាន ក្នុងការរួមចំណែកការពារអធិបតេយ្យភាពជាតិ បូរណភាពដែនដី និងការអភិវឌ្ឍប្រទេសជាតិ។ លើសពីនេះ ក្នុងពេលកម្ពុជាធ្វើជាប្រធានអាស៊ាននៅឆ្នាំ២០១២ កម្ពុជាបានសម្រេចបាននូវ «**សេចក្តីថ្លែងការណ៍អាស៊ានស្តីពីសិទ្ធិមនុស្ស**» ដែលប្រមុខរដ្ឋ/ប្រមុខរដ្ឋាភិបាល អាស៊ាន បានអនុម័តក្នុងពេលកិច្ចប្រជុំកំពូលអាស៊ានលើកទី២១ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១២ នៅទីក្រុង ភ្នំពេញ។ នេះជាលើកទីមួយក្នុងប្រវត្តិសាស្ត្រអាស៊ាន ដែលប្រមុខរដ្ឋ/ប្រមុខរដ្ឋាភិបាលអាស៊ានបានចេញសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិមនុស្ស។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏មានការប្តេជ្ញាខ្ពស់ផងដែរ ក្នុងការវាយបំបាក់ និងទប់ស្កាត់រាល់សកម្មភាពនិងល្បិចកលក្រោមផ្លាក «**លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស**» បំរើផលប្រយោជន៍នយោបាយរបស់បុគ្គល ឬក្រុមមនុស្សមួយក្តាប់តូច។*

ក្នុងស្មារតីបង្រួបបង្រួមជាតិ រាជរដ្ឋាភិបាលបាននឹងកំពុងអនុវត្ត «វប្បធម៌សន្ទនា» ដែលជាមូលដ្ឋានក្នុងការពិភាក្សាដោះស្រាយដោយសន្តិវិធីនូវរាល់បញ្ហាជាតិ និងសង្គម ដោយភាពស្មោះត្រង់ជាមួយគ្នា គោរព និងឲ្យតម្លៃគ្នាទៅវិញទៅមក។ នេះគឺជា បុរេល័ក្ខខ័ណ្ឌដ៏សំខាន់មួយទៀត ដែលផ្ដល់នូវភាពជឿជាក់លើការបន្តបោះជំហានទៅមុខរបស់កម្ពុជា។

កម្ពុជាក៏បានដើរតួនាទីយ៉ាងសកម្មក្នុងការចូលរួមចំណែកដោះស្រាយបញ្ហាប្រឈមនានានៅក្នុងពិភពលោក និងក្នុងតំបន់បច្ចុប្បន្ន ជាមួយសហគមន៍អន្តរជាតិក្នុងការការពារ និងថែរក្សាសន្តិភាពនៅលើសាកលលោក។

ក្នុងន័យនេះ កម្ពុជាបានចូលរួមជាភាគីនៃសន្ធិសញ្ញា និងពិធីសារអន្តរជាតិជាច្រើនពាក់ព័ន្ធនឹងការកាត់បន្ថយសព្វាវុធ ការទប់ស្កាត់ការរីកសាយអាវុធប្រល័យលោក កម្ពុជាក៏បានចូលរួមយ៉ាងសកម្មក្នុងកិច្ចសហប្រតិបត្តិការថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ តាមរយៈការបញ្ជូនក្រុមប្រតិបត្តិការដោះមីន កងរក្សាសណ្ដាប់ធ្នាប់ កងវិស្វកម្ម មន្ទីរពេទ្យកម្រិត២ ចាប់តាំងពីឆ្នាំ២០០៦ រហូតមកដល់បច្ចុប្បន្ននេះមានចំនួនជាង ៣,០០០នាក់ នៅប្រទេសស៊ូដង់ ស៊ូដង់ខាងត្បូង ឆាដ សាធារណរដ្ឋ អាហ្វ្រិកកណ្ដាល ស៊ីរី លីបង់ ម៉ាលី និងស៊ីប្រ។

ជាទីបញ្ចប់ ខ្ញុំសូមអំពាវនាវដល់ជនរួមជាតិ ព្រមទាំងអង្គការអន្តរជាតិនិងសង្គមស៊ីវិលទាំងអស់នៅកម្ពុជា សូមបន្តពួតដៃគ្នាអនុវត្តនិងគាំទ្រស្មារតី«**ទិវាសន្តិភាពអន្តរជាតិ**»នេះ និងបន្តអនុវត្ត «វប្បធម៌សន្ទនា» ឲ្យបានខ្ជាប់ខ្ជួន និងបន្តខិតខំថែបំប៉ន ពង្រឹងនិងផ្សព្វផ្សាយឲ្យបានទូលំទូលាយនូវការយល់ដឹងអំពីគ្រឹះមូលដ្ឋានទ្រទ្រង់សន្តិភាព ដែលមានជាអាទិ៍ ការលើកកម្ពស់វប្បធម៌អហិង្សា ការអត់ធ្មត់ ការយោគយល់ ការអធ្យាស្រ័យគ្នា ការសន្តោសប្រណី ការស្រលាញ់រាប់អានគ្នាជាភាតរៈនៅក្នុងសង្គមជាតិរបស់យើង។

ឆ្លៀតឱកាសនេះ ខ្ញុំសូមប្រសិទ្ធពរជូនជនរួមជាតិជាទីស្នេហា សូមបានប្រកបដោយពុទ្ធពរទាំង៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០១៥

ហ៊ុន សែន